CITY OF LONGBEACH

# PRESS RELEASE

ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០២០

ទំនាក់ទំនង: មជ្ឈមណ្ឌលពត៌មានរួម សាលាក្រុងឡុងប៊ីឆ, 562.570.NEWS,
jic@longbeach.gov

សំរាប់ផ្សព្វផ្សាយបន្ទាន់

## ទីក្រុងឡុងប៊ិចប្រកាសអាសន្នក្នុងតំបន់ និងចេញបញ្ជាបំរាមគោចរ នៅទូទាំងក្រុងយប់នេះ

ក្រុងឡុងប៊ីឆ, រដ្ឋកាលីហ្វ័រញ៉ា — ថ្ងៃនេះ, ទីក្រុងឡុងប៊ិចបានប្រកាស អាសន្នក្នុងតំបន់ទូទាំងទីក្រុង និង បំរាមគោចរទូទាំងទីក្រុង ដែលចូលជាធរមាន ឬមានប្រសិទ្ធភាពនៅម៉ោង ៨ យប់។

អភិបាលក្រុង Robert Garcia មានប្រសាសន៍ថា “អាមេរិចដែលមានភាពចំរុះគ្នារបស់យើង មានប្រវត្តិងងឹត និងវែងជាមួយការប្រណាំង - ហើយឡុងប៊ិច មិនត្រូវបានលើកលែង ពីបញ្ហានេះឡើយ។ ក្នុងរយៈពេលជាច្រើនថ្ងៃចុងក្រោយនេះ និងបន្ទាប់ពីបានប្រយុទ្ធជាមួយជំងឺ COVID-19 អស់រយៈពេលជិតបីខែនេះ ក្នុងនាមជាប្រជាជាតិមួយ, យើងកំពុងឃើញភាពវឹកវរស៊ីវិល និងការតវ៉ានានា។ យើងឮអ្នក ហើយកំពុងតែស្តាប់,”។
“ក្នុងរយៈពេលពីរបីថ្ងៃខាងមុខនេះ យើងរំពឹងថានឹងឃើញសកម្មភាពនានា និងការធ្វើបាតុកម្មនៅឡុងប៊ិច និងសម្រាប់អ្នកដែល កំពុងជ្រើសរើសចូលរួម, វាជាការសំខាន់ណាស់ ដែលអ្នកត្រូវអនុវត្តសិទ្ធិនូវវិសោធនកម្ម លើកទីមួយរបស់អ្នកដោយសុវត្ថិភាព និងគ្មានគ្រោះថ្នាក់ដល់ជីវិត ឬទ្រព្យសម្បត្តិ។ ចូរថែរក្សាគ្នា និង ថែរក្សាសហគមន៍របស់យើង។ ឡុងប៊ិចមានមោទនភាពចំពោះភាពចម្រុះរបស់យើង និងការ ដើរក្បួនដ៏វែងរបស់យើង ឆ្ពោះទៅរកយុត្តិធម៌។ យើងអាចធ្វើបានល្អជាង - ហើយយើងនឹងធ្វើ.”។

មានប្រសិទ្ធភាពភ្លាមៗ, បំរាមគោចរត្រូវបានបញ្ជា ចាប់ពីម៉ោង ៨ យប់ ទៅដល់ម៉ោង ៥ ព្រឹក នៅក្នុងទីក្រុងឡុងប៊ិច។ គ្មានជនណាម្នាក់ នឹងត្រូវធ្វើដំណើរ ឬនៅលើ/នៅតាមផ្លូវសាធារណៈនានា, ដងវិថី, ផ្លូវដើរតូចៗចន្លោះអាគារ, សួនច្បារ, ផ្លូវតូចៗ ឬកន្លែងសាធារណៈណាមួយផ្សេង ទៀត នៅក្នុងទីក្រុងឡុងប៊ិចបានទេ ក្នុងរយៈពេលនៃបំរាមគោចរនេះ, លើកលែងតែមានការអនុញ្ញាតិយ៉ាងច្បាស់លាស់តែប៉ុណ្ណោះ។ សំរាប់គោលបំណងនានា នៃបទបញ្ញត្តិបំរាមគោចរនេះ, “ការធ្វើដំណើរ” នឹងរួមបញ្ចូល, តែមិនត្រូវបានកំណត់ចំពោះ, ការធ្វើដំណើរដោយថ្មើរជើង, កង់, ស្គីក្តារ, ស្កូតធ័រ (scooter), ម៉ូតូ ឬរថយន្ត ឬមធ្យោបាយដឹកជញ្ជូន/បញ្ជូន ផ្សេងទៀតឡើយ។

បុគ្គលិកអនុវត្តច្បាប់, បុគ្គលិកពន្លត់អគ្គីភ័យ, អ្នកផ្តល់សេវាថែទាំសុខភាពបន្ទាន់, បុគ្គលិកពេទ្យបន្ទាន់, ជនស៊ីវិលដែលចូលរួមក្នុងការរក្សាសណ្តាប់ធ្នាប់/ប៉ូលីស ឬការងារបន្ទាន់, បុគ្គលដែលស្វែងរកការសង្គ្រោះបន្ទាន់, បុគ្គលដែលធ្វើដំណើរទៅ និងមកពីកន្លែងធ្វើការរបស់ពួកគេ និងអ្នកតំណាងសារព័ត៌មានទាំងឡាយ, ត្រូវបានលើកលែង។

អ្នកគ្រប់គ្រងទីក្រុង Tom Modica, ក្នុងនាមជាប្រធានការពារជនស៊ីវិលនៃទីក្រុងឡុងប៊ិច, ថ្ងៃនេះបាន ប្រកាសអាសន្នក្នុងតំបន់ក្នុងទីក្រុងឡុងប៊ិច និងបានបញ្ជាអោយមាននូវបំរាមគោចរតាមអំណាចទាំងឡាយនានា ដែលមានចែងក្នុងក្រម/ច្បាប់ក្រុង។

នៅថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០២០, ដោយសារតែសកម្មភាពអស្ថិរភាពស៊ីវិលនានា
និងធនធាន ក្នុងតំបន់មានកំរិត, អភិបាលរដ្ឋ Gavin Newsom
បានចេញសេចក្តីប្រកាសអាសន្នរដ្ឋ សំរាប់ ខោនធី ឡូសអានចែលឡេសទាំងអស់
ហើយបានដឹកនាំប្រជាជនទាំងឡាយ អោយគោរពតាម
ដំបូន្មានរបស់មន្ត្រីសង្គ្រោះបន្ទាន់ក្នុងតំបន់។ ក្រមក្រុង នៃក្រុងឡុងប៊ិចលេខ ២.៦៩ ផ្តល់សិទ្ធិអំណាចដល់ប្រធានការពារជនស៊ីវិល (អ្នកគ្រប់គ្រងទីក្រុង) ដើម្បីធ្វើសេចក្តីប្រកាស, ពីប្រធានបទនៃការផ្តល់សច្ចាប័នដោយក្រុមប្រឹក្សាក្រុង ក្នុងរយៈពេល ៧ ថ្ងៃ, អត្ថិភាព (ការមាន) ឬអត្ថិភាពដែលមានការគំរាមកំហែង នៃភាពអាសន្នក្នុងតំបន់ នៅពេលដែល ទីក្រុងបាន ទទួលរងផលប៉ះពាល់ ឬទំនងជាត្រូវទទួលរងផលប៉ះពាល់ ដោយ សារគ្រោះមហន្តរាយ ឬភាពអាសន្នដ៏ធំ ហើយក្រុមប្រឹក្សាមិនស្ថិតក្នុងសម័យប្រជុំបាន។

បំរាមគោចរនេះនឹងនៅមានប្រសិទ្ធិភាព រហូតដល់ម៉ោង ៥ ព្រឹក ថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០២០, លើកលែងតែមានការពន្យារពេល ប្រសិនបើស្ថានការណ៍ត្រូវបានធានា។

###